# សារៈសំខាន់នៃការអប់រំ

បទគម្ពីរ និងសេចក្ដីថ្លែងការណ៍ខាងក្រោមនេះមកពីថ្នាក់ដឹកនាំសាសនាចក្រ អាចជួយអ្នកឲ្យយល់កាន់តែច្រើនអំពីការរំពឹងទុក និងបំណងប្រាថ្នារបស់ព្រះអម្ចាស់សម្រាប់អ្នកដើម្បីទទួលបានការអប់រំ ។ ពេលអ្នកសិក្សា សូមស្វែងរកសេចក្ដីពិតអំពីសារៈសំខាន់នៃការអប់រំ ។

**បទគម្ពីរដែលត្រូវសិក្សា ៖**

គោលលទ្ធិ និងសេចក្ដីសញ្ញា ៨៨:៧៧-៨០, ១១៨; ១៣០:១៨–១៩

**ការបង្រៀនមកពីថ្នាក់ដឹកនាំសាសនាចក្រ ៖**

ប្រធាន រ័សុល អិម ណិលសុន បានបង្រៀន ៖



> ការអប់រំគឺជាអ្វីដែលអ្នកត្រូវទទួល ។ គ្មាននរណាផ្សេងអាចទទួលវាសម្រាប់អ្នកបានឡើយ ។ មិនថាអ្នកនៅកន្លែងណាទេ សូមបង្កើតនូវបំណងប្រាថ្នាខ្លាំងដើម្បីរៀនសូត្រ ។ ចំពោះយើងដែលជាពួកបរិសុទ្ធថ្ងៃចុងក្រោយ ការទទួលបានការអប់រំពុំមែនគ្រាន់តែជាឯកសិទ្ធិមួយប៉ុណ្ណោះទេ តែវាជាការទទួលខុសត្រូវខាងសាសនាមួយផងដែរ ។ « សិរីល្អនៃព្រះគឺជាបញ្ញា » ( គោលលទ្ធិ និងសេចក្ដីសញ្ញា ៩៣:៣៦ ) ប្រាកដណាស់ការអប់រំរបស់យើងនឹងនៅយូរអង្វែងដល់អស់កល្បជានិច្ច ។ . . .
>
> ទស្សនៈរយៈពេលយូរដូច្នោះ នឹងជួយអ្នកធ្វើការជ្រើសរើសល្អពីការអប់រំ ។
>
> ចូរកុំខ្លាចក្នុងការតោងចាប់គោលដៅអ្នកឡើយ—ទោះជាសុបិនអ្នកក្ដី ! ប៉ុន្តែសូមដឹងថា គ្មានផ្លូវកាត់ណាដើម្បីបានឧត្តមភាព និងមានសមត្ថភាពនោះទេ ។ ការអប់រំគឺខុសប្លែកពី *ការប៉ងប្រាថ្នា* អ្នកអាចជួយអ្នកដទៃ និង *មានលទ្ធភាព* អាចជួយដល់ពួកគេបាន ។ ( រ័សុល អិម ណិលសុន « What Will You Choose? » *Ensign* ខែមករា ឆ្នាំ២០១៥ ទំព័រ ៣២ )

អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ ៖



> អ្នក និងខ្ញុំនៅទីនេះនៅលើផែនដីដើម្បីរៀបចំខ្លួនសម្រាប់ភាពអស់កល្បជានិច្ច ដើម្បីរៀនអំពីរបៀបរៀនសូត្រ រៀនអ្វីដែលសំខាន់ជាបណ្ដោះអាសន្ន និងសំខាន់អស់កល្បជានិច្ច ហើយដើម្បីជួយអ្នកដទៃក្នុងការរៀនសូត្រពីប្រាជ្ញា និងសេចក្ដីពិត ( សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា ៩៧:១ ) ។ ការយល់ដឹងថាយើងជានរណា យើងមកពីណា ហើយហេតុអ្វីយើងនៅលើផែនដីដែលយើងម្នាក់ៗមានទំនួលខុសត្រូវយ៉ាងខ្លាំងទាំងការរៀនដើម្បីដឹងពីរបៀបរៀន និងរៀនដើម្បីស្រឡាញ់ការរៀន ។ ( ដាវីឌ អេ បែដណា « Learning to Love Learning » *Ensign* ខែកុម្ភៈ ឆ្នាំ២០១០ ទំព័រ ២៧ )

ប្រធាន ខាំមៀល អិន ចនសុន ប្រធានសមាគមសង្គ្រោះទូទៅ បានបង្រៀនថា ៖



> យើងគួរតែទទួលការអប់រំ និងការបណ្ដុះបណ្ដាលទាំងអស់ដែលយើងអាចធ្វើបានដើម្បីយើងអាចរៀបចំខ្លួនបាន ។ រៀបចំខ្លួនដើម្បីបម្រើនៅក្នុងលោកិយ និងសាសនាចក្រ ។ រៀបចំខ្លួនធ្វើជាទីប្រឹក្សា និងដៃគូដ៏ឈ្លាសវៃចំពោះស្វាមីភរិយារបស់យើង ។ រៀបចំខ្លួនធ្វើជាគ្រូបង្រៀនដ៏មានប្រសិទ្ធភាពដល់កូនៗរបស់យើង និងយុវវ័យទាំងនោះដែលយើងមានឥទ្ធិពលលើ ។ កាលណាយើងកាន់តែរៀន នោះឥទ្ធិពលកាន់តែខ្លាំងដែលយើងអាចមានសម្រាប់សេចក្ដីល្អ » ។ ( ខាំមៀល អិន ចនសុន« Seek Learning by Study and by Faith » [ ការប្រជុំធម្មនិដ្ឋានទូទាំងពិភពលោក BYU–Pathway ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២១ ] នៅលើគេហទំព័រ byupathway.org ) ។

ចេញមកពី *ដើម្បីកម្លាំងនៃយុវជន ៖ សេចក្ដីណែនាំដើម្បីធ្វើការជ្រើសរើស* ៖

> ព្រះវរបិតាសួគ៌មានព្រះទ័យចង់ឲ្យបុត្រា និងបុត្រីរបស់ទ្រង់រៀនសូត្រជានិច្ច ។ អ្នកមានហេតុផលទាំងខាងសាច់ឈាម និងខាងវិញ្ញាណក្នុងការស្វែងរក និងការស្រឡាញ់ការរៀនសូត្រ ។ ការអប់រំមិនមែនគ្រាន់តែអំពីការរកប្រាក់ប៉ុណ្ណោះនោះទេ ។ ការអប់រំគឺជាផ្នែកមួយនៃគោលដៅដ៏អស់កល្បជានិច្ចរបស់អ្នកដើម្បីប្រែក្លាយកាន់តែដូចជាព្រះវរបិតាសួគ៌ ។. . .
>
> សូមស្វែងរកឱកាសដើម្បីពង្រីកគំនិត និងជំនាញរបស់អ្នក ។ ឱកាសទាំងនេះអាចរួមបញ្ចូលការអប់រំជាផ្លូវការនៅសាលា ឬការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក៏ដូចជាការរៀនក្រៅផ្លូវការមកពីប្រភពដែលអ្នកទុកចិត្តបានផងដែរ ។ សូមយាងព្រះអម្ចាស់ឲ្យមានចំណែកនៅក្នុងការខិតខំរបស់អ្នក ហើយទ្រង់នឹងដឹកនាំអ្នក ។ នៅពេលអ្នករៀនអំពីពិភពលោកជុំវិញអ្នក សូមរៀនផងដែរអំពីព្រះអង្គសង្គ្រោះដែលបានបង្កើតពិភពលោកនេះ ។ សូមសិក្សាអំពីព្រះជន្ម និងការបង្រៀនរបស់ទ្រង់ ។ សូមធ្វើឲ្យថ្នាក់សិក្ខាសាលា ថ្នាក់វិទ្យាស្ថាន និងការសិក្សាដំណឹងល្អផ្ទាល់ខ្លួនក្លាយជាផ្នែកមួយនៃការសិក្សាពេញមួយជីវិតរបស់អ្នក ។ ( *ដើម្បីកម្លាំងនៃយុវជន ៖សេចក្ដីណែនាំដើម្បីធ្វើការជ្រើសរើស* [ ឆ្នាំ២០២២ ] ទំព័រ ៣១ )

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2024 by Intellectual Reserve, Inc. All rights reserved. PD80007812_258_581-1